# វិធីដាំមៀន/គាវ៉ែន

## ១. ការរៀបចំរណ្ដៅ:

- ត្រូវជីករណ្ដៅ ៦តឹកបួនជ្រុង និង ជំរៅ ៦តឹក




- រោយកំបោរសប្រមាណ២ស្លាបព្រាបាយក្នុងរណ្ដៅ។
- ត្រូវដាក់ផេះ ឬ អង្កាម, កំប្លោក, ចំបើង ពុក, អាចម៍មាន់ឬអាចម៍ជ្រូក ឬអាចម៍គោមួយស្រទាប់កំរាស់១តឹក រួចដាក់ដីពីលើ ១តឹកធ្វើយ៉ាងនេះ រហូតទាល់តែពេញរណ្ដៅ។




- ត្រូវទុករណ្ដៅរៀបចំហើយក្នុងរយៈពេល ២ ទៅ ៣អាទិត្យ។



- ចំងាយពីរណ្ដៅមួយទៅរណ្ដៅមួយ មានប្រវែង ៦ ម៉ែត្រ។

## ២. ការដាំ:

- កូនមៀនត្រូវរក្សាផ្សាំទុក ១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹក២ថ្ងៃមុនដាំដើម្បីកុំអោយបែកដី និងឫស។
- ជញ្ជូនកូនមៀនដាក់ក្បែររណ្ដៅ ទាំងអស់។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- ដាំកូនមៀនក្នុងរណ្ដៅ កប់ដីកន្ទោងស្មើមាត់រណ្ដៅ រួចយកមែកឈើដោតក្បែរចងទប់ ជាមួយកូនមៀនការពារខ្យល់បក់។
- រោយដីបន្តិចម្ដងៗដោយសង្កត់ថ្នមៗជុំវិញដីកន្ទោង ហាមសង្កត់លើដីកន្ទោងកូនមៀនដែលបណ្ដាលអោយដាច់ឫស។



## ៣. ការថែទាំ និងដាក់ជី:

- ខែវស្សារត្រូវពូនគល់ការពារទឹកដាំនៅគល់បណ្ដាលអោយរលួយឫស។



- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉ន ដោយប្រើជីអាចម៍មាន់ ឬអាចម៍ជ្រូក ឬអាចម៍គោលាយជាមួយអង្កាមពុក, ចំបើង ឬកំប្លោករលួយកាយកប់ក្នុងដីធ្វើជាកំពែង។
- ប្រសិនបើកូនមៀនមានសត្វល្អិតស៊ីត្រួយត្រូវប្រើថ្នាំសំលាប់សត្វល្អិត (ណាហ្គា)។
- នៅពេល ផ្លែមៀនមានទំហំប៉ុនមេដៃយើងត្រូវបាញ់ថ្នាំសំលាប់សត្វល្អិត(ណាហ្គា)ទៅលើផ្លែដើម្បីការពារដង្កូវស៊ីផ្លែពេលវាទុំ។



## ៤. ការស្រោចទឹក:

- កូនមៀនអាយុតិចជាង២ឆ្នាំ ត្រូវស្រោចទឹក ១ដងក្នុង១អាទិត្យនៅរដូវប្រាំង។
- យើងត្រូវស្រោចទឹកតែម្ដងគត់នៅពេលវាកំពុងផ្កា។